**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: ២៩៥៣ប្រ.ក

# ប្រកាស
# ស្តីពី
# ការកំណត់រូបភាព របៀបប្រើប្រាស់ និងរបបផ្តល់ជូន ឯកសណ្ឋាន ស្លាកសញ្ញាសញ្ញាសក្តិនិងសម្ភារប្រើប្រាស់ផ្សេងៗ របស់មន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២០១ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ស្តីពីឯកសណ្ឋាន ស្លាកសញ្ញា និងសញ្ញាសក្តិមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២០២អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកំណត់សមមូលឋានន្តរសក្តិមន្ត្រីពន្ធនាគារ ជាមួយនឹងឋានន្តរសក្តិមន្ត្រីរាជការស៊ីវិល និងឋានន្តរសក្តិមន្ត្រីនគរបាលជាតិនិងការធ្វើសមាហរណកម្មទៅក្នុងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់ក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ១.-**

រូបភាពម៉ូត ឃ្នាតនិងរបៀបប្រើប្រាស់ឯកសណ្ឋានរបស់មន្ត្រីពន្ធនាគារត្រូវបានរៀបចំនិងកំណត់ដូចខាងក្រោម:

*ក-ឯកសណ្ឋានថ្នាក់ឧត្តមអគ្គានុរក្ស មាន ០៦ ប្រភេទគឺ:*

*ក.១-ឯកសណ្ឋានធំលេខ ១ "រ៉ាំរីពណ៌ស"*

១-ឯកសណ្ឋានធំលេខ ១ : សម្រាប់ប្រើប្រាស់ក្នុងព្រះរាជពិធីបុណ្យជាតិ ។

២- រូបភាព និងម៉ូត :

- អាវរ៉ាំរីពណ៌ស:ដៃវែង កបើក ប៉ូលស្មា និងឆែកខ្នងមួយ។អាវនេះមានហោប៉ៅចំនួនបួនហោប៉ៅខាងលើមានចំនួនពីរ(ហោប៉ៅប៉ះ)ចំកណ្តាលមានជីបផ្ទត់មួយ និងហោប៉ៅខាងក្រោមមានចំនួនពីរ(ហោប៉ៅកាត់)គម្របហោប៉ៅទាំងបួនរាងចតុកោណកែងតែគម្របខាងក្រោមសងខាងនិងកណ្តាលរាងស្រួច។ ពីចុងដៃអាវទាំងសងខាងឡើងមកលើប្រវែង៨០ម.ម មានប៉ានភ្ជីក្បាច់ផ្កាដូងពណ៌មាសព័ទ្ធជុំវិញដៃអាវទំហំទទឹងប្រវែង១៥ម.ម អាវនេះមានឡេវរូបព្រះសង្ការពណ៌មាសចំនួនបួនគ្រាប់និងមានឡេវរូបព្រះសង្ការពណ៌មាសចំនួនបីគ្រាប់ដាក់បញ្ឆោត។

- ខោ : ជើងវែងពណ៌បៃតងចង្កេះត និងគ្មានគ្លី។ ហោប៉ៅខោមានចំនួនបី គឺហោប៉ៅខាងក្រោយមានចំនួនមួយ(ហោប៉ៅកាត់)គ្មានគម្រប ចោះរន្ធដាក់ឡេវមួយគ្រាប់។ ហោប៉ៅចំហៀងសងខាងមានចំនួនពីរដេរបង្កប់តាមថ្នេរខោពីថ្នេរចង្កេះខោរហូតដល់ចុងជើងខោទាំងសងខាងមានប៉ានឆ្នូតពីរពណ៌លឿង ប៉ាននីមួយៗមានទំហំទទឹងប្រវែង១៥ ម.ម។

- អាវសឺមីកខុប ដៃវែងពណ៌សពាក់ខាងក្នុង។ អាវនេះមានហោប៉ៅមួយគ្មានគម្របកាត់ស្រុងដាក់ក្នុងខោ។

-ក្រវ៉ាត់កពណ៌ផ្កាឈូកខ្ចី ឃ្នាបក្រវ៉ាត់កមានរូបសញ្ញាអគ្គនាយកដ្ឋានពន្ធនាគារប្រភេទ ៤ ពណ៌មាសនៅចំកណ្តាល ។

- មួកកាស្កេតធ្វើអំពីក្រណាត់ពណ៌ស។ ជើងមួកផ្នែកខាងមុខមានប៉ាក់ក្បាច់ភ្ជីផ្កាដូង និងភ្ជីវល្លិពណ៌មាសភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌មាសចំនួនពីរគ្រាប់។ នៅលើក្បាំងមួកមានប៉ាក់ក្បាច់ភ្ជីទេសពណ៌មាសពីចុងម្ខាងដល់ចុងម្ខាង។ នៅលើមុខមួកមានដាក់រូបព្រះសង្ការពណ៌មាសប្រភេទ ១។

- ខ្សែឥស្សរិយយសពណ៌មាស ពាក់នៅលើស្មាខាងស្តាំ(បន្តោកជាមួយឡេវអាវខាងលើ)

- ស្រោមដៃពណ៌ស

- ខ្សែក្រវ៉ាត់តូចពណ៌ខ្មៅ ។ ក្បាលខ្សែក្រវ៉ាត់ពណ៌មាស មានរូបសញ្ញាអគ្គនាយកដ្ឋានពន្ធនាគារនៅចំកណ្តាល។

- ស្បែកជើងកខ្លីពណ៌ខ្មៅចងខ្សែ និងស្រោមជើងពណ៌ខ្មៅ ។

*ក.២- ឯកសណ្ឋានធំលេខ ២ : "រ៉ាំរីពណ៌ខ្លាញ់ក្តាមចាស់"*

១-ឯកសណ្ឋានធំលេខ ២ សម្រាប់ប្រើប្រាស់ក្នុងពិធីផ្លូវការនានា និងការទទួលភ្ញៀវជាតិ អន្តរជាតិ។

២-រូបភាព និងម៉ូត :

- អាវរ៉ាំរីពណ៌ខ្លាញ់ក្តាមចាស់ : ដៃវែង កបើក ប៉ូលស្មា និងឆែកខ្នងមួយ។ អាវនេះមានហោប៉ៅចំនួនបួន ហោប៉ៅខាងលើមានចំនួនពីរ(ហោប៉ៅប៉ះ)ចំកណ្តាលមានជីបផ្ទត់មួយ និងហោប៉ៅខាងក្រោមមានចំនួនពីរ(ហោប៉ៅកាត់) គម្របហោប៉ៅទាំងបួនរាងចតុកោណកែង តែគម្របខាងក្រោមសងខាង និងកណ្តាលរាងស្រួច។ អាវនេះមានឡេវរូបព្រះសង្ការពណ៌មាសចំនួនបួនគ្រាប់ និងនៅចុងដៃអាវម្ខាងៗ មានឡេវរូបព្រះសង្ការពណ៌មាសចំនួនបីគ្រាប់ដាក់បញ្ឆោត។

-ខោ : ជើងវែងពណ៌ខ្លាញ់ក្តាមចាស់ ថ្នេរបង្កប់ ចង្កេះត និងគ្មានគ្លី។ ហោប៉ៅមានចំនួនបី គឺហោប៉ៅខាងក្រោយមានចំនួនមួយដេរបង្កប់គ្មានគម្រប និងហោប៉ៅចំហៀងទាំងសងខាងដេរបង្កប់តាមថ្នេរខោ។

- មួកការស្កេតធ្វើអំពីក្រណាត់ពណ៌ខ្លាញ់ក្ដាមចាស់ ឯរូបភាពនិងម៉ូតដូចមួកការស្កេតក្នុងឯកសណ្ឋានធំលេខ ១ ។

- អាវសឺមីកឌុប ដៃវែងពណ៌ផ្ទៃមេឃពាក់ខាងក្នុង។ អាវនេះមានហោប៉ៅមួយ គ្មានគម្រប កាត់ស្រុងដាក់ក្នុងខោ។

- ក្រវ៉ាត់ក ខ្សែឥស្សរិយយស ស្រោមដៃ ខ្សែក្រវ៉ាត់ ស្បែកជើង និងស្រោមជើង ដូចក្នុងឯកសណ្ឋានធំលេខ ១ ។

មន្ត្រីពន្ធនាគារអាចប្រើប្រាស់ឯកសណ្ឋានធំលេខ ១ *"វ៉ារីពណ៌ស"* និង*ឯកសណ្ឋានធំលេខ ២ : " វ៉ារីពណ៌ខ្លាញ់ក្ដាមចាស់"* សម្រាប់ពិធីរៀបអាពាហ៍ពិពាហ៍ផ្ទាល់ខ្លួន។

*ក.៣. ឯកសណ្ឋានលេខ ៣: " សាហារីយ៉ែន "*

១-ឯកសណ្ឋានលេខ ៣សម្រាប់ប្រើប្រាស់ក្នុងពិធីមិទ្ទិញសិក្ខាសាលានិងសន្និបាតនានា។

២-រូបភាព និងម៉ូត :

- អាវសាហារីយ៉ែន : ពណ៌កាគីចាស់ កឌុប ដៃខ្លី ជីវបកចុងដៃ កាត់រាងអាវធំមានប៉ូលស្មា និងឆែកខ្នង។ អាវនេះមានហោប៉ៅចំនួនបួន ហោប៉ៅខាងលើមានចំនួនពីរ និងហោប៉ៅខាងក្រោមមានចំនួនពីរ(ដេរប៉ះ)នៅចំកណ្ដាលមានបត់ផ្នត់មួយ។ គម្របហោប៉ៅទាំងបួនរាងចតុកោណកែង តែគម្របខាងក្រោមសងខាង និងកណ្ដាលរាងស្រួច។ អាវនេះជីវបកខ្លួនមានខ្សែរធ្វើអំពីជ័រពណ៌កាគីចាស់ដែលមានអង្កត់ផ្ចិតទំហំ ១៥ ម.ម។

- ខោ : ជើងវែងពណ៌កាគីចាស់ ថ្ពេរបង្កប់ចង្កេះត និងគ្មានក្លី។ ហោប៉ៅខោមានចំនួនបួន ហោប៉ៅក្រោយមានចំនួនពីរដេរបង្កប់ គ្មានគម្រប ចោះរន្ធដាក់ឡេវចំនួនមួយគ្រាប់ និងហោប៉ៅចំហៀងសងខាងដេរបង្កប់តាមថ្ពេរខោ ។

- មួកការស្កេត ដូចឯកសណ្ឋានធំលេខ ២

- ខ្សែក្រវ៉ាត់ ស្បែកជើង និងស្រោមជើង ដូចឯកសណ្ឋានធំលេខ ១។

*ក.៤. ឯកសណ្ឋានការងារលេខ ៤:*

១-ឯកសណ្ឋានការងារលេខ ៤ សំរាប់ប្រើប្រាស់ក្នុងពេលបំពេញការងារប្រចាំថ្ងៃ។

២-រូបភាព និងម៉ូត

- អាវដៃវែង ពណ៌កាគីចាស់ កឌុប មានប៉ូលស្មា។ កាត់ស្រុងជើងអាវត្រង់ដាក់ក្នុងខោ មានហោប៉ៅខាងលើចំនួនពីរ(ដេរប៉ះ) នៅចំកណ្ដាលបត់ផ្នត់មួយ គម្របហោប៉ៅមានរាងស្លឹកពោធិ៍។ អាវនេះមានជីវបកខ្លួន និងឡេវធ្វើអំពីជ័រពណ៌កាគីចាស់។

- ខោ : ដូចឯកសណ្ឋានលេខ ៣

- មួកការស្កេតដូចឯកសណ្ឋានធំលេខ២ ឬមួកហ្សកកីពណ៌ខ្លាញ់ក្ដាមចាស់ កាត់ចេញជា៦ជ្រុងដេរតេបំបែកសង្កត់ថ្ពេរសងខាងមួយទំហំ ៣ម.ម និងមានវាយភ្នែកមាន់ពណ៌ខ្មៅតាមជ្រុងនីមួយៗ ផ្នែកខាងលើ១/៣នៃជ្រុងស្រួចនៅលើក្បាំងមួកមានប៉ាក់ផ្កាភ្ញីទេសពណ៌មាសពីជើងម្ខាងដល់ជើងម្ខាង នៅលើមុខមួកមានព្រះសង្ហារប្រភេទ ២ ។

-ខ្សែក្រវ៉ាត់ស្បែកជើង និងស្រោមជើង ដូចឯកសណ្ឋានធំលេខ ១។

*ក.៥. ឯកសណ្ឋានការងារលេខ ៥*

១-ឯកសណ្ឋានការងារលេខ៥ សំរាប់ប្រើប្រាស់ក្នុងពេលបំពេញការងារប្រចាំថ្ងៃ។

២- រូបភាព និងម៉ូត

- អាវដៃខ្លី ពណ៌កាគីចាស់ កខុប មានប៉ូលស្មា ជីបកបុងដៃអាវ។ កាត់រាងស្រួច ជើងអាវត្រង់ដាក់ក្នុងខោ។ អាវនេះមានហោប៉ៅចំនួនពីរ(ដេរប៉ះ)នៅចំកណ្តាលបត់ផ្នត់មួយ គម្របហោប៉ៅមានរាងស្លឹកពោធិ៍។ អាវនេះមានជីបកខ្លួន និងឡេវធ្វើអំពីជ័រពណ៌កាគីចាស់។

- ខោ : ដូចឯកសណ្ឋានលេខ ៣

- មួកកាស្កេត ដូចឯកសណ្ឋានធំលេខ ២ ឬមួកហ៊្សែកកី ដូចឯកសណ្ឋានការងារលេខ ៤

- ខ្សែក្រវ៉ាត់ ស្បែកជើង និងស្រោមជើង ដូចឯកសណ្ឋានធំលេខ ១។

*ក.៦. ឯកសណ្ឋានប្រតិបត្តិការលេខ ៦*

១- ឯកសណ្ឋានលេខ ៦ ក្រណាត់កាគីពណ៌បៃតងចាស់ សម្រាប់ប្រើប្រាស់ក្នុងប្រតិបត្តិការរក្សាសន្តិសុខ សុវត្ថិភាព យាមប៉ុស្តិ៍ ប៉ម ការពារជនជាប់ឃុំឡើងសវនាការ និងការដឹកបញ្ជូនជនជាប់ឃុំ។

២-រូបភាព និងម៉ូត

- អាវនេះមានរូបភាព និងម៉ូត ដូចឯកសណ្ឋានប្រតិបត្តិការរបស់កងកម្លាំងនគរបាលជាតិ។ អាវនេះមានហោប៉ៅចំនួនបួន ហោប៉ៅខាងលើមានចំនួនពីរ ហោប៉ៅខាងក្រោមមានចំនួនពីរ(ហោប៉ៅស្បោង) ជីបមាត់ចាបចំកណ្តាល តួហោប៉ៅមូល ហោប៉ៅទាំងបួនមានគម្របបញ្ឆិតសន្ទះអណ្តាតចោះរន្ធដាក់ឡេវបង្កប់ ហោប៉ៅអាវខាងលើដាក់ឡេវចំនួនមួយគ្រាប់ ហោប៉ៅអាវខាងក្រោមដាក់ឡេវចំនួនពីរគ្រាប់(ពណ៌ដូចអាវ) អាវដៃបំពង់ ចុងដៃអាវមានប៉ូលដាក់ឡេវចំនួនពីរគ្រាប់។

- ខោ : ចង្កេះលាត ប៉ាននិងជីបក្បាលជង្គង់ នៅសងខាងចង្កេះខោមានខ្សែរឹត។ ខោមានហោប៉ៅចំនួនប្រាំមួយ ហោប៉ៅខាងក្រោយមានចំនួនពីរ ហោប៉ៅកាត់គម្របបញ្ឆិតសន្ទះអណ្តាតចោះរន្ធដាក់ឡេវមួយគ្រាប់ ហោប៉ៅចំហៀងសងខាងមានចំនួនពីរ(ហោប៉ៅបញ្ឆិត) ហោប៉ៅជង្គង់មានចំនួនពីរ(ហោប៉ៅស្បោង) មានជីបផ្នត់ពីរ តួហោប៉ៅជ្រុង គម្របបញ្ឆិតមានសន្ទះអណ្តាតចោះរន្ធដាក់ឡេវចំនួនពីរគ្រាប់ ឡេវមានពណ៌ដូចខោ ចុងជើងខោមានខ្សែចង ។

- មួកដែក(ស្នាច់)ស្រោបក្រណាត់ពណ៌ខ្លាញ់ក្តាមចាស់ ដាក់រូបព្រះសង្ការប្រភេទ ២ នៅចំពីមុខមួក នៅលើរឹមមួកផ្នែកខាងស្តាំមានអក្សរមូលពណ៌លឿង សរសេរកាត់ថា " ម.៣" និងផ្នែកខាងឆ្វេងមានអក្សរឡាតាំងពុម្ពពណ៌លឿង សរសេរកាត់ថា " P.O" និងមានខ្សែភ្ជោះកណ្តាលក្រវ៉ាត់ទ្រក្រោមចង្កា ឬមួកហ្សុកកី ដូចឯកសណ្ឋានការងារលេខ ៤។

- ខ្សែក្រវ៉ាត់តូចពណ៌ខ្មៅ ដូចឯកសណ្ឋានការងារលេខ ៤

- ខ្សែក្រវ៉ាត់ធំ "សាំងទៀរ៉ុង"ពណ៌បៃតងចាស់ ដោយមានខ្សែយោងសងខាងពណ៌បៃតងក្រវ៉ាត់ពីក្រៅអាវ

- ស្បែកជើងកវែងពណ៌ខ្មៅ ខ្សែរូត ស្រោមជើងពណ៌ខ្មៅ ហើយជើងខោបញ្ចូលក្នុងកស្បែកជើង។

- អាវយឺតដៃខ្លី កខុបពណ៌ប្រផេះ ខាងក្រោយខ្នងមានអក្សរឡាតាំងពណ៌ខ្មៅ សរសេរកាត់ថា G.D.P ខាងមុខផ្នែកខាងឆ្វេងមានដាក់ស្លាកសញ្ញាអគ្គនាយកដ្ឋានពន្ធនាគារប្រភេទ ១ និងនៅខាងក្រោមស្លាកសញ្ញាមានអក្សរពណ៌ខ្មៅរាងស្តែងក្របី សរសេរថា **អគ្គនាយកដ្ឋានពន្ធនាគារ**។

*ខ. ឯកសណ្ឋានថ្នាក់វរអគ្គានុរក្ស មាន ៦ ប្រភេទ គឺ :*

រូបភាព ម៉ូត និងរបៀបប្រើប្រាស់ដូចឯកសណ្ឋានថ្នាក់ឧត្តមអគ្គានុរក្សដែរ ប៉ុន្តែមានចំណុចខុសគ្នាមួយចំនួន ដូចខាងក្រោម : ស

ខ.១. ក្បាច់កដៃអាវឯកសណ្ឋានធំលេខ១(អាវពណ៌ស)មានប៉ានក្រណាត់លាតពណ៌លឿង ។

ខ.២. ប៉ានធ្នូតពីរពណ៌លឿង នៃខោឯកសណ្ឋានធំលេខ ១ ប៉ាននីមួយៗមានទំហំទទឹងប្រវែង ១០ ម.ម ។

ខ.៣. មួកកាស្កេត នៅលើជើងមុខមួកមានខ្សែសូតាសភ្លោះ ពណ៌មាសវេញបញ្ចូលគ្នាបីផ្លុង និងនៅលើគែមក្បាំងមួកមានក្បាច់ភ្ញីទេសពណ៌មាសដែលមានចុងឃ្លាតពីជើងមួកទាំងសងខាងចំងាយប្រវែង ៤០ ម.ម ។

ខ.៤. មួកហ្សុកកី នៅលើក្បាំងមួកមានប៉ាក់ផ្កាភ្ញីទេសពណ៌មាស ដូចមួកថ្នាក់ឧត្តមអគ្គានុរក្សដែរ គ្រាន់តែមួកថ្នាក់វរអគ្គានុរក្សមានក្បាច់ឃ្លាតសងខាងជើងក្បាំងប្រវែង ៧០ ម.ម។

*គ. ឯកសណ្ឋានថ្នាក់អគ្គានុរក្ស និងថ្នាក់អនុរក្សពន្ធនាគារ*

ឯកសណ្ឋានថ្នាក់អគ្គានុរក្ស និងថ្នាក់អនុរក្សមាន ២ ប្រភេទគឺ ឯកសណ្ឋានការងារលេខ៤ និងលេខ ៥ ឬឯកសណ្ឋានប្រតិបត្តិការលេខ ៦។ សម្រាប់មន្ត្រីថ្នាក់អគ្គានុរក្ស និងមន្ត្រីថ្នាក់អនុរក្សក្នុងប្រតិបត្តិការទូទៅ(ក្រៅពីផ្នែកសន្តិសុខ អន្តរាគមន៍) ត្រូវប្រើប្រាស់ឯកសណ្ឋានការងារលេខ ៤ និងលេខ ៥។ សម្រាប់មន្ត្រីថ្នាក់អគ្គានុរក្ស និងមន្ត្រីថ្នាក់អនុរក្សក្នុងផ្នែកសន្តិសុខ អន្តរាគមន៍ត្រូវប្រើប្រាស់ឯកសណ្ឋានប្រតិបត្តិការលេខ ៦ (ម្នាក់ ០២ កំប្លេរ)។

រូបភាព ម៉ូត និងរបៀបប្រើប្រាស់ដូចឯកសណ្ឋានថ្នាក់វរអគ្គានុរក្សដែរ ប៉ុន្តែមានចំណុចខុសគ្នាមួយចំនួន ដូចខាងក្រោម :

*គ១. ថ្នាក់អគ្គានុរក្ស*

- មួកកាស្កេត នៅលើជើងមុខមួក មានខ្សែសូតាសភ្លោះពណ៌មាស វេញបញ្ចូលគ្នាបីផ្លុង និងនៅលើគែមក្បាំងមួកមានខ្សែសូតាសភ្លោះពណ៌មាសមួយខ្សែ។
- មួកហ្សុកកី នៅលើក្បាំងមួកមានខ្សែសូតាសរាងកន្ទុយកណ្តុរពណ៌មាសទំហំ ៥ ម.ម ព័ទ្ធជុំវិញក្បាំងពីម្ខាងដល់ម្ខាង។
- ខ្សែកញ្ចែពណ៌មង្សុត ពាក់នៅលើស្មាខាងស្តាំ(បន្តោកនៅហោប៉ៅអាវ)

*គ២. ថ្នាក់អនុរក្ស*

- មួកកាស្កេត នៅលើជើងមុខមួកមានខ្សែសយស់ប៉ែតមួយបន្ទះពណ៌ប្រាក់ មានទទឹងប្រវែង ១៤ ម.ម ភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌ប្រាក់ចំនួនពីរគ្រាប់។
- មួកហ្សុកកី ដូចមួកថ្នាក់អគ្គានុរក្សដែរ ប៉ុន្តែនៅលើក្បាំងមួកលាតទាំងអស់។
- ខ្សែកញ្ចែ(ដូចថ្នាក់អគ្គានុរក្ស)។

មន្ត្រីថ្នាក់អគ្គានុរក្ស និងមន្ត្រីថ្នាក់អនុរក្សពន្ធនាគារ នៅពេលចូលរួមពិធីប្រជុំផ្សេងៗ ត្រូវស្លៀកពាក់ឯកសណ្ឋានការងារលេខ ៤ ពាក់ក្រវ៉ាត់កពណ៌ផ្កាឈូកខ្ចី ឃ្នាបក្រវ៉ាត់ករូបស្លាកសញ្ញាអគ្គនាយកដ្ឋានពន្ធនាគារប្រភេទ ៤ ពណ៌ប្រាក់នៅចំកណ្តាល ឬពាក់អាវយឺតកឱប ពណ៌ប្រផេះ។

*ឃ. ឯកសណ្ឋានមន្ត្រីពន្ធនាគារនារី*

ឃ.១.ឯកសណ្ឋានមន្ត្រីពន្ធនាគារនារី ស្រដៀងឯកសណ្ឋានមន្ត្រីពន្ធនាគារបុរសដែរ ប៉ុន្តែមានចំណុចមួយចំនួនខុសគ្នា ដូចខាងក្រោម :

*១- ឯកសណ្ឋានធំលេខ ១ "ភរិពណ៌ស"*

- អាវ : មានរូបភាព និងម៉ូតដូចអាវបុរសដែរ ប៉ុន្តែកាត់តាមរបៀបជាអាវនារី
- សំពត់ : ដឹមីស្វារ៉េត្រឹមក្បាលជង្គង់ ប៉ានធ្វូតពីពណ៌លឿងព័ទ្ធជុំវិញជើងសំពត់ ចង្កេះត និងខាងក្រោយមានផែកគងមួយ ។
- មួកសំបុកពណ៌ស
- ស្បែកជើងកខ្លីពណ៌ខ្មៅ(អេស្កាប៉ាំង) និងស្រោមជើងពណ៌សាច់

*២- ឯកសណ្ឋានធំលេខ ២ "ភរិពណ៌ខ្វាញ់ក្ដាមចាស់"*

- អាវ : មានរូបភាព និងម៉ូតដូចអាវបុរសដែរ ប៉ុន្តែកាត់តាមរបៀបជាអាវនារី
- សំពត់ : ដឹមីស្វារ៉េត្រឹមក្បាលជង្គង់ ចង្កេះត និងខាងក្រោយមានផែកគងមួយ។
- មួកសំបុកពណ៌ខ្លាញ់ក្តាមចាស់
- ស្បែកជើង និងស្រោមជើង ដូចឯកសណ្ឋានធំលេខ ១

*៣-ឯកសណ្ឋានលេខ ៣ (សាហារីយ៉ែន)*

- អាវ : មានរូបភាព និងម៉ូតដូចអាវបុរសដែរ ប៉ុន្តែកាត់តាមរបៀបជាអាវនារី
- សំពត់ : ដឹមីស្វារ៉េ ត្រឹមក្បាលជង្គង់ ចង្កេះត និងខាងក្រោយផែកគងមួយ។
- មួកសំបុកពណ៌ខ្លាញ់ក្តាមចាស់
- ស្បែកជើង និងស្រោមជើង ដូចឯកសណ្ឋានធំលេខ ១

*៤- ឯកសណ្ឋានការងារលេខ ៤ និងលេខ៥* : រូបភាព ម៉ូត និងរបៀបប្រើប្រាស់ដូចបុរសដែរ ប៉ុន្តែស្លៀកពាក់ជាមួយសំពត់ (សំពត់ដូចឯកសណ្ឋានលេខ៣)។ ដោយឡែកចំពោះឯកសណ្ឋានប្រតិបត្តិការលេខ ៦ រូបភាព ម៉ូត និងរបៀបប្រើប្រាស់ ដូចបុរស(ស្លៀកពាក់ជាមួយខោ)។

- មួកសំបុក ឬហ៊្សកកីពណ៌ខ្លាញ់ក្តាមចាស់។

*ឃ.២.* មួកសំបុកមន្ត្រីពន្ធនាគារនារី មានរូបភាពដូចខាងក្រោម :

១- មួកសំបុកមន្ត្រីពន្ធនាគារនារីថ្នាក់ឧត្តមអគ្គានុរក្ស : នៅលើមុខមួកមានដាក់រូបព្រះសង្ហាពណ៌មាសប្រភេទ២ និងនៅជើងមុខមួកមានប៉ាក់ក្បាច់ភ្ញីផ្កាដូងនិងភ្ញីល្វើ ពណ៌មាស ភ្ជាប់ដោយឡេវរូបព្រះសង្ហារពណ៌មាសចំនួនពីរគ្រាប់ និងនៅលើក្បាំងមួកមានប៉ាក់ក្បាច់ភ្ញីទេសពណ៌មាស។

២- មួកសំបុកមន្ត្រីពន្ធនាគារនារីថ្នាក់វរអគ្គានុរក្ស : នៅលើមុខមួកមានដាក់រូបព្រះសង្ហារពណ៌មាសប្រភេទ២ នៅជើងមុខមួកមានខ្សែសូតាសភ្លោះពណ៌មាសវេញបញ្ចូលគ្នាបីផ្លូងមួយខ្សែ និងនៅលើក្បាំងមួកមានប៉ាក់ក្បាច់ភ្ញីទេសពណ៌មាស។

៣- មួកសំបុកមន្ត្រីពន្ធនាគារនារីថ្នាក់អគ្គានុរក្ស : នៅលើមុខមួកមានដាក់រូបព្រះសង្ហារពណ៌មាសប្រភេទ ២ នៅជើងមុខមួកមានខ្សែសូតាសភ្លោះពណ៌មាសវេញបញ្ចូលគ្នាបីផ្លូង និងនៅលើក្បាំងមួកមានមានខ្សែសូតាសពណ៌មាសមួយខ្សែ។

៤- មួកសំបុកមន្ត្រីពន្ធនាគារនារីថ្នាក់អនុរក្ស : នៅលើមុខមួកមានដាក់រូបព្រះសង្ហារពណ៌មាសប្រភេទ ២ និងនៅជើងមុខមួកមានខ្សែសយសំប៉ែតពណ៌ប្រាក់មួយបន្ទះ ។

**ប្រការ២.**

រូបសញ្ញា និងស្លាកសញ្ញារបស់មន្ត្រីពន្ធនាគារ ត្រូវបានកំណត់ដូចខាងក្រោម :

ក- រូបព្រះសង្ហារ មាន ៣ ប្រភេទ គឺ :

១- រូបព្រះសង្ការប្រភេទ ១ : ពណ៌មាសសម្រាប់ដាក់លើមុខមួកកាស្កេត។ រូបព្រះសង្ការប្រភេទនេះមានទំហំកំពស់ ៧៨ ម.ម និងទទឹង ៧១ ម.ម ។

២- រូបព្រះសង្ការប្រភេទ២ : ពណ៌មាសសម្រាប់ដាក់លើមុខមួកហ្សិកកី និងមួកសំបុកមន្ត្រីពន្ធនាគារនារី ។ ព្រះសង្ការប្រភេទនេះមានទំហំកំពស់ ៥៣ ម.ម និងទទឹង ៥៤ ម.ម ។

៣- រូបព្រះសង្ការប្រភេទ ៣ : ពណ៌មាសផ្ទៃពណ៌ស រឹមព័ទ្ធជុំវិញពណ៌មាស និងមានរូបកំរងកួរស្រូវពណ៌មាសអមលំអទ្រទ្រូវរូបព្រះសង្ការាងជាស្នែងក្របី
សម្រាប់ដាក់លើចំហៀងមួកបេរ៉េតផ្នែកខាងឆ្វេង។ ព្រះសង្ការប្រភេទនេះមានទំហំកំពស់ ៤៥ ម.ម និងទទឹង ៥៥ ម.ម ។

ខ- ស្លាកសញ្ញាមន្ត្រីពន្ធនាគារៈ មាន ៥ ប្រភេទគឺ :

១-ស្លាកសញ្ញាប្រភេទ ១ : សម្រាប់ពាក់បន្តោកនៅឡេវហោប៉ៅអាវខាងស្តាំ ។

ស្លាកសញ្ញាប្រភេទនេះធ្វើរាងជាខែល ដែលមានស្បែកបន្តោកប្រវែង ១០០ម.ម បាតស្រួចពណ៌ខៀវចាស់។ នៅលើស្បែកបន្តោកមានស្លាកសញ្ញារាងមូល អង្កត់ផ្ចិត ៤៩ម.ម ផ្ទៃពណ៌ខៀវចាស់ នៅចំកណ្តាលផ្ទៃមានរូបសញ្ញាអគ្គនាយកដ្ឋានពន្ធនាគារពណ៌ទង់ដែង ពន្លឺពណ៌ប្រាក់នៅខាងក្រោមរូបសញ្ញាអគ្គនាយកដ្ឋានពន្ធនាគារ មានអក្សរមូលពណ៌ប្រាក់សរសេរកាត់ថា "**ម.ព.ភ**" ហើយមានរូបកងចក្រពណ៌ប្រាក់ភ្លឺមានកាំចំនួន ២១ ព័ទ្ធជុំវិញ។

២-ស្លាកសញ្ញាប្រភេទ ២: សម្រាប់ដាក់លើដៃអាវខាងស្តាំចុះពីថ្នេរស្មាចំងាយ ៧៥ ម.ម ។ ស្លាកសញ្ញាប្រភេទនេះធ្វើអំពីក្រណាត់រាងមូលផ្ទៃពណ៌ទង់ជាតិមានអង្កត់ផ្ចិតប្រវែង៧៧ ម.ម រឹមព័ទ្ធជុំវិញពណ៌ស ទទឹង ២ ម.ម នៅខាងលើមួយភាគបួនមានផ្ទៃពណ៌ខៀវ ដែលមានអក្សរមូល ពណ៌សសរសេរថា "**ក្រសួងមហាផ្ទៃ**" អក្សរកំពស់ ១២ ម.ម ។ នៅផ្នែកខាងក្រោមលើផ្ទៃពណ៌ខៀវមាន អក្សរពណ៌ស សរសេរថា "**អគ្គនាយកដ្ឋានពន្ធនាគារ**" អក្សរកម្ពស់ ១០ ម.ម នៅចំកណ្តាលលើផ្ទៃ ពណ៌ក្រហមមានរូបប្រាសាទកំពូលបីពណ៌ស ប្រាសាទមានទំហំកម្ពស់ ២២ ម.ម បាតប្រវែង ៣៤ម.ម ។

៣-ស្លាកសញ្ញាប្រភេទ ៣: សម្រាប់ដាក់លើដៃអាវខាងឆ្វេង។ ស្លាកសញ្ញាប្រភេទនេះធ្វើអំពីក្រណាត់មានពីរស្លាក។ ស្លាកទី១ ចុះពីថ្នេរស្មាចំងាយ៥០ ម.មរាងកោងផ្ទៃពណ៌ទង់ជាតិ ទំហំបណ្តោយខាងលើប្រវែង ១០៥ម.មបណ្តោយខាងក្រោមប្រវែង ៧០ ម.ម និងទទឹងប្រវែង ២៥ ម.ម មានរឹមព័ទ្ធជុំវិញពណ៌ស ទទឹងប្រវែង ១.៥ ម.ម ហើយនៅចំកណ្តាលផ្ទៃពណ៌ក្រហម មានអក្សរមូលពណ៌ស សរសេរថា "**ពន្ធនាគារកម្ពុជា** " អក្សរកម្ពស់ ៨ ម.ម។ស្លាកទី២ស្ថិតនៅខាងក្រោមស្លាករាងកោងមានរាងខែល (រូបសញ្ញាអគ្គនាយកដ្ឋានពន្ធនាគារ) ដែលមានទំហំបណ្តោយប្រវែង ៨៣ម.ម កម្ពស់ ៨៩ម.ម មានរឹមពណ៌ទង់ជាតិ មានផ្ទៃពណ៌ទង់ដែងនៅចំកណ្តាលផ្ទៃមានរូបកូនសោរពីរ(ចុងសោរឡើងលើ) ពណ៌មាស នៅខាងលើចុងកូនសោរមានអក្សរមូលពណ៌មាសសរសេរកាត់ថា "**ម.ព**" អក្សរកម្ពស់១២ ម.ម នៅខាងក្រោមក្បាលកូនសោរមានអក្សរឡាតាំងពណ៌មាសសរសេរកាត់ថា "P.O" អក្សរកម្ពស់ ១០ម.ម និងនៅផ្នែកខាងក្រោមនៃខែលមានអក្សរមូលពណ៌ស សរសេរថា "**ពន្ធនាគារកម្ពុជា**" អក្សរកម្ពស់ ៨ ម.ម។

៤-ស្លាកសញ្ញាប្រភេទ ៤ : សម្រាប់ពាក់នៅលើចុងកអាវទាំងសងខាងនៃ[illegible] លេខ១២៣៤៥ និង ៦។ ចំពោះថ្នាក់ឧត្តមអគ្គានុរក្សនិងវរអគ្គានុរក្សត្រូវប្រើស្លាកសញ្ញាប្រភេទនេះពណ៌មាស រីឯថ្នាក់អគ្គានុរក្សចុះត្រូវប្រើស្លាកសញ្ញាប្រភេទនេះពណ៌ប្រាក់ភ្លឺ ។

ស្លាកសញ្ញាប្រភេទនេះមានរាងមូលអង្កត់ផ្ចិត២៦ ម.ម ដែលមានរូបកូនសោរពីរ(ចុងឡើងលើ) ខ្វែងគ្នាទ្រជើងពានតម្កល់រដ្ឋធម្មនុញ្ញ ហើយមានរូបកម្រងកួរស្រូវអមលម្អទ្រទ្រង់ជារាងស្នែងក្របី។

៥- ស្លាកសញ្ញាសម្គាល់ឈ្មោះនិងអត្តលេខ : ស្លាកនេះសម្រាប់ពាក់នៅលើគម្របហោប៉ៅអាវលើខាងស្តាំ មានរាងទ្រវែងបណ្តោយប្រវែង១០ ស.ម ទទឹង ២ស.ម ធ្វើអំពីជ័ររឹង ផ្ទៃពណ៌ខៀវខ្ចី មានរឹមបន្ទាត់ពណ៌សព័ទ្ធជុំវិញ។ ស្លាកនេះមានសរសេរសម្គាល់ឋានន្តរសក្តិ(អក្សរកាត់)នៅពីមុខនាមត្រកូល និងនាមខ្លួនមន្ត្រីនៅជួរខាងលើជាអក្សរខ្មែរ(អក្សរពុម្ព) និងអត្តលេខជាលេខឡាតាំង ពណ៌ទឹកមាស ដែលមានកម្ពស់អក្សរ ០,៥ស.ម និងកម្ពស់លេខ ០,៤ស.ម។ អក្សរកាត់សម្គាល់ឋានន្តរសក្តិ គឺ :

- ថ្នាក់ឧត្តមអគ្គានុរក្សពន្ធនាគារ កំណត់អក្សរ **ឧ**
- ថ្នាក់វរអគ្គានុរក្សពន្ធនាគារ កំណត់អក្សរ **វ**
- ថ្នាក់អគ្គានុរក្សពន្ធនាគារ កំណត់អក្សរ **អ**
- ថ្នាក់អនុរក្សពន្ធនាគារ កំណត់អក្សរ **អ.ន**

អត្តលេខមន្ត្រីពន្ធនាគារគឺជាលេខសម្គាល់ខ្លួនរបស់សាមីមន្ត្រីម្នាក់ៗ ត្រូវបានកំណត់តាមមុខងារ ឬលំដាប់ឋានន្តរសក្តិ ដោយពុំគិតពីអតីតភាពការងារឡើយ។ ការរៀបចំអត្តលេខ គឺកំណត់ចំនួនបួនខ្ទង់ចាប់ពី ០០០១ រហូតដល់ចុងបញ្ចប់នៃចំនួនមន្ត្រីជាក់ស្តែង ចំពោះមន្ត្រីដែលបានផ្ទេរចូលឬជ្រើសរើសក្របខ័ណ្ឌថ្មី ត្រូវរៀបចំអត្តលេខតាមលេខរៀងបន្ត។ ដោយឡែកចំពោះមន្ត្រីដែលបានផ្ទេរចេញ ឬសុំលាឈប់ ឬលប់ឈ្មោះចេញពីក្របខ័ណ្ឌ មិនត្រូវយកអត្តលេខទាំងនោះទៅប្រើប្រាស់បន្តឡើយ។

គ- សញ្ញាសម្គាល់អតីតភាពការងារមន្ត្រីពន្ធនាគារ : មាន ២ ប្រភេទគឺ :

១- សញ្ញាអតីតភាពប្រភេទ ១ :

សញ្ញាអតីតភាពប្រភេទ ១ មានរូបមេអំបៅ និងជើងទម្រ ពណ៌មាស ដែលមានទទឹងទំហំ៦០ ម.ម កម្ពស់ ៣០ម.ម ។ សញ្ញាអតីតភាពប្រភេទ ១ នេះ ប្រើសម្រាប់ឋានន្តរសក្តិពីថ្នាក់វរអគ្គានុរក្សឡើង។

២- សញ្ញាអតីតភាពប្រភេទ ២ :

សញ្ញាអតីតភាពប្រភេទ ២ មានរូបមេអំបៅ និងជើងទម្រ ពណ៌ប្រាក់ដែលមានទទឹងទំហំ៦០ ម.ម កម្ពស់ ៣០ម.ម ។ សញ្ញាអតីតភាពប្រភេទ ២ នេះ ប្រើសម្រាប់ឋានន្តរសក្តិពីថ្នាក់អគ្គានុរក្សចុះ។

រូបសញ្ញាសម្គាល់អតីតភាពការងារតំណាងឱ្យ :

- រូបមេអំបៅតំណាងឱ្យបរិស្ថានល្អ
- រូបភ្លើនៅលើស្លាបមេអំបៅតំណាងឱ្យសន្តិសុខនិងសុវត្ថិភាព
- រូបត្បូងពណ៌សតំណាងឱ្យអតីតភាពការងារ
  + ត្បូង ១គ្រាប់ ចំកណ្តាលតួមេអំបៅតំណាងឱ្យអតីតភាពការងារ ១០ឆ្នាំចុះ
  + ត្បូង ២គ្រាប់នៅលើស្លាបសងខាងតំណាងឱ្យអតីតភាពការងារពី១១ឆ្នាំ ដល់២០ឆ្នាំ
  + ត្បូង ៣គ្រាប់ ចំស្លាបសងខាងនិងចំកណ្តាលតួមេអំបៅតំណាងឱ្យអតីតភាពការងារពី ២១ឆ្នាំឡើង ។
- រូបជើងទម្រតំណាងឱ្យការលើកកម្ពស់សន្តិសុខ និងភាពរឹងមាំ។

សម្រាប់សញ្ញាសម្គាល់(LOGO) ប្រើប្រាស់សម្គាល់នៅលើទីតាំងអង្គភាព ឬមធ្យោបាយ ឬកន្លែងពិធីការឬឯកសារផ្លូវការនានា ត្រូវបានកំណត់យកស្លាកទី២នៃស្លាកសញ្ញាប្រភេទ៣ ដោយមានអក្សររាងស្វែងក្របី សរសេរថា **ក្រសួងមហាផ្ទៃ** នៅខាងលើ និងមាន អក្សររាងស្វែងក្របី សរសេរថា **អគ្គនាយកដ្ឋានពន្ធនាគារ** នៅខាងក្រោមស្លាកនេះ។

**ប្រការ៣.—**

រូបភាពលំដាប់សញ្ញាសក្តិរបស់មន្ត្រីពន្ធនាគារ ត្រូវបានរៀបចំដូចខាងក្រោម ៖

**ក. សក្តិថ្នាក់ឧត្តមអគ្គានុរក្សពន្ធនាគារ មាន ៣ ប្រភេទ ៖**

*១. សក្តិស្មាប្រភេទ ១*

សក្តិស្មាប្រភេទ ១ សម្រាប់ប្រើប្រាស់ក្នុងព្រះរាជពិធីបុណ្យជាតិ ហើយសម្រាប់ពាក់នៅលើឯកសណ្ឋានលេខ ១ "អាវ៉ាវីពណ៌ស"។ សក្តិស្មាប្រភេទនេះមានរាងទ្រវែងចុងស្រួច ធ្វើអំពីក្រណាត់កាំម្វីផ្ទៃពណ៌ទឹកមាស មានផ្កាយពណ៌មាសជាសញ្ញាសម្គាល់សក្តិថ្នាក់ឧត្តមអគ្គានុរក្ស មានកូនសោរពីរ( ចុងសោរឡើងលើ )ខ្វែងគ្នាទ្រជើងពានតម្កល់រង្វេជមុនុញ្ញក្នុងម្កុដរាជពណ៌មាស មានឡេវរូបព្រះសង្ការពណ៌មាស និងមានក្បាច់ភ្ញីផ្កាដូងនិងភ្ញីវល្លិ ពណ៌មាសកាត់ទទឹងផ្នែកខាងដើមផ្ទៃសក្តិ។

អំពីខ្នាត ៖

- បណ្តោយប្រវែង ១២៥ ម.ម
- ទទឹងខាងដើមប្រវែង ៥៧ ម.ម
- ទទឹងកណ្តាលប្រវែង ៤៧ ម.ម
- ទទឹងខាងចុងប្រវែង ៤២ ម.ម
- ប្រវែងបញ្ចិតខាងចុង ២៥ ម.ម
- ក្បាច់ផ្កាភ្ញីទទឹងប្រវែង ១៥ ម.ម
- ទំហំម្កុដ និងកូនសោរទ្រ កម្ពស់ ៣៧ ម.ម
- ឡេវរូបព្រះរាជសង្ការបន្ទាត់ផ្ចិត ១៥ ម.ម

របៀបដាក់ផ្កាយ ៖

- ឧត្តមអគ្គានុរក្សថ្នាក់លេខ៣ មានផ្កាយពណ៌មាសមួយ រៀបឃ្លាតពីក្បាច់ភ្ញីផ្កាដូងនិងភ្ញីវល្លិ ប្រវែង ២៧ មម
- ឧត្តមអគ្គានុរក្សថ្នាក់លេខ២ មានផ្កាយពណ៌មាសពីររៀបទន្ទឹមគ្នាជាជួរតាមបណ្តោយផ្ទៃសក្តិ
- ឧត្តមអគ្គានុរក្សថ្នាក់លេខ១ មានផ្កាយពណ៌មាសបី រៀបទន្ទឹមគ្នាជាជួរតាមបណ្តោយផ្ទៃសក្តិ

ទំហំផ្កាយ ៖

- ផ្កាយមានរង្វង់ផ្ចិតប្រវែង ១៨ ម.ម
- កម្ពស់ផ្កាយប្រវែង ០៦ ម.ម

*២. សក្តិស្មាប្រភេទ ២*

សក្តិស្មាប្រភេទ ២ សម្រាប់ប្រើប្រាស់ជាផ្លូវការនានា ពិធីទទួលភ្ញៀវជាតិ អន្តរជាតិ ពិធីមិទ្ទីញ សិក្ខាសាលា សន្និបាត និងសម្រាប់ប្រើប្រាស់ក្នុងពេលបំពេញការងារប្រចាំថ្ងៃ ហើយសម្រាប់ពាក់នៅលើឯកសណ្ឋានលេខ២ លេខ៣ លេខ៤ និងលេខ៥។ សក្តិស្មាប្រភេទនេះធ្វើអំពីក្រណាត់កាំម្វីពណ៌ខៀវចាស់មានរាងចតុកោណព្នាយជ្រុងផ្នែកខាងចុង មានផ្កាយពណ៌មាសជាសញ្ញាសម្គាល់សក្តិថ្នាក់ឧត្តមអគ្គានុរក្ស មានរូបកូនសោរពីរ( ចុងសោរឡើងលើ )ខ្វែងគ្នាទ្រជើងពានតម្កល់រង្វេជមុនុញ្ញក្នុងម្កុដរាជពណ៌មាស មានឡេវរូបព្រះសង្ការពណ៌មាស និងមានក្បាច់ភ្ញីផ្កាដូងនិងភ្ញីវល្លិពណ៌មាស កាត់ទទឹងផ្នែកខាងដើមផ្ទៃសក្តិ ។

អំពីខ្នាត :

- បណ្ដោយប្រវែង ១២០ ម.ម
- ទទឹងខាងដើមប្រវែង ៥៧ ម.ម
- ទទឹងកណ្ដាលប្រវែង ៤៧ ម.ម
- ទទឹងខាងចុងប្រវែង ៤២ ម.ម
- ក្បាច់ផ្កាភ្ញីទទឹងប្រវែង ១៥ ម.ម
- ទំហំម្កុដ និងកូនសោរទ្រ កម្ពស់ ៣៧ ម.ម
- ឡេវរូបព្រះសង្ការបន្ទាត់ផ្ចិត ១៥ ម.ម

ទំហំផ្កាយ :

- ផ្កាយមានរង្វង់ផ្ចិតប្រវែង ១៨ ម.ម
- កម្ពស់ផ្កាយប្រវែង ០៦ ម.ម

*៣. សក្តិប្រភេទ៣ "សក្តិទ្រូង"*

សក្តិប្រភេទ៣ សម្រាប់ពាក់នៅលើទ្រូងនៃឯកសណ្ឋានលេខ៦ "ឯកសណ្ឋានប្រតិបត្តិការ"។ សក្តិប្រភេទនេះមានរាងបួនជ្រុងស្មើ ធ្វើអំពីក្រណាត់កាំម្ញីពណ៌ខៀវចាស់ មានផ្កាយពណ៌មាស មានកូនសោរពីរ(ចុងសោរឡើងលើ) ខ្វែងគ្នាទ្រដើងពានតម្កល់រង្វេធម្មនុញ្ញក្នុងម្កុដរាជពណ៌មាស និងមានក្បាច់ភ្ញីផ្កាជួងនិងភ្ញីល្អិតពណ៌មាស កាត់ទទឹងផ្នែកខាងដើមផ្ទៃសក្តិ(ប៉ាក់ដោយខ្សែសយ)។

អំពីខ្នាត :

- បណ្ដោយប្រវែង ៤២ ម.ម
- ទទឹងប្រវែង ៤២ ម.ម
- ទំហំម្កុដនិងកូនសោរទ្រ កម្ពស់ ២២ ម.ម

អំពីទំហំផ្កាយ :

- រង្វង់ផ្ចិត ០៦ ម.ម
- កម្ពស់ ២.៥០ ម.ម

របៀបដាក់ផ្កាយ : មានលក្ខណៈដូចសក្តិស្មា។

**ខ. សក្តិថ្នាក់វរអគ្គានុរក្សពន្ធនាគារ ៣ ប្រភេទ**

*១. សក្តិស្មាប្រភេទ ១*

សក្តិស្មាប្រភេទ១ សម្រាប់ប្រើប្រាស់ជាផ្លូវការក្នុងព្រះរាជពិធីបុណ្យជាតិ ហើយសម្រាប់ពាក់នៅលើឯកសណ្ឋានលេខ ១ "អាវ៉ារីពណ៌ស"។ សក្តិស្មាប្រភេទនេះ មានរាងទ្រវែងចុងស្រួចធ្វើអំពីក្រណាត់កាំម្ញីមានផ្ទៃពណ៌ទឹកមាស មានរូបកូនសោរពីរខ្វែងគ្នាទ្រដើងពានតម្កល់រង្វេធម្មនុញ្ញក្នុងម្កុដរាជពណ៌មាស មានឡេវរូបព្រះសង្ការពណ៌មាស និងមានក្បាច់ភ្ញីផ្កាចន្ទន៍និងភ្ញីល្អិតពណ៌មាស កាត់ទទឹងផ្នែកខាងដើមផ្ទៃសក្តិ ហើយឆ្នូតសក្តិកាត់ទទឹងជាសញ្ញាសម្គាល់សក្តិថ្នាក់វរអគ្គានុរក្សពន្ធនាគារ ។

អំពីទំហំខ្នាត : (ដូចសក្តិថ្នាក់ឧត្តមអគ្គានុរក្ស)

*២. សក្តិស្មាប្រភេទ ២*

សក្តិប្រភេទ២ ប្រើប្រាស់ជាផ្លូវការក្នុងពិធីបុណ្យជាតិ អន្តរជាតិ ទទួលគណៈប្រតិភូបរទេស និងក្នុងពេលបំពេញការងារប្រចាំថ្ងៃ សម្រាប់ពាក់នៅលើឯកសណ្ឋានលេខ ២ លេខ ៣ លេខ ៤ និង៨

លេខ ៥។ សក្តិស្មាប្រភេទនេះធ្វើអំពីក្រណាត់កាំម្វីពណ៌ខៀវចាស់ មានរាងចតុកោណព្នាយជ្រុងផ្នែកខាងចុងមានកូនសោរពីរ(ចុងសោរឡើងលើ) ខ្វែងគ្នាទ្រជើងពានតម្កល់វដ្តធម្មនុញ្ញក្នុងម្កុដរាជពណ៌មាស មានឡេវរូបព្រះសង្ការពណ៌មាស និងមានក្បាច់ភ្ញីផ្កាចន្ទន៍និងភ្ញីវល្លិពណ៌មាសកាត់ទទឹងផ្នែកខាងដើមផ្ទៃសក្តិ ហើយធ្នូតសក្តិកាត់ទទឹងជាសញ្ញាសម្គាល់សក្តិថ្នាក់វរអគ្គានុរក្សពន្ធនាគារ។ ប៉ុន្តែចំពោះថ្នាក់វរអគ្គានុរក្សថ្នាក់លេខ ២មានធ្នូតកាត់ទទឹងមួយពណ៌ប្រាក់(ធ្នូតទី៥)និងធ្នូតបួនទៀតពណ៌មាស។

អំពីទំហំខ្នាត : (ដូចសក្តិថ្នាក់ឧត្តមអគ្គានុរក្ស)

របៀបរៀបចំរូបភាពសញ្ញាសក្តិ : រៀបតាមលំដាប់ពីក្រោមមកលើ

- ទទឹងធ្នូតទំហំ ៨ ម.ម
- ធ្នូតនីមួយៗ ឃ្លាតគ្នាប្រវែង ២ ម.ម
- ដោយឡែកពីធ្នូតទី ៣ ទៅធ្នូតទី ៤ ឃ្លាតគ្នាប្រវែង ៧ ម.ម ។

របៀបរៀបចំរូបភាពសញ្ញាសក្តិ :

- វរអគ្គានុរក្សថ្នាក់លេខ ១ មានធ្នូតពណ៌មាស ៥
- វរអគ្គានុរក្សថ្នាក់លេខ ២ មានធ្នូតពណ៌មាស ៤ និងធ្នូតពណ៌ប្រាក់ ១ (ធ្នូតទី៥)
- វរអគ្គានុរក្សថ្នាក់លេខ ៣ មានធ្នូតពណ៌មាស ៤

*៣. សក្តិប្រភេទ៣ "សក្តិទ្រូង"*

សក្តិប្រភេទ៣នេះ សម្រាប់ពាក់នៅលើទ្រូងនៃឯកសណ្ឋានលេខ៦"ឯកសណ្ឋានប្រតិបត្តិការ"។ សក្តិប្រភេទនេះមានរាងបួនជ្រុងស្មើធ្វើអំពីក្រណាត់កាំម្វីពណ៌ខៀវចាស់ ហើយមានធ្នូតកាត់ទទឹងជាសញ្ញាសម្គាល់សក្តិ មានកូនសោរពីរ(ចុងសោរឡើងលើ)ខ្វែងគ្នាទ្រជើងពានតម្កល់វដ្តធម្មនុញ្ញក្នុងម្កុដរាជ និងមានក្បាច់ភ្ញីផ្កាចន្ទន៍និងភ្ញីវល្លិពណ៌មាស កាត់ទទឹងផ្នែកខាងដើមផ្ទៃសក្តិ(ប៉ាក់ដោយខ្សែសយ)។

អំពីទំហំខ្នាត : (ដូចសក្តិថ្នាក់ឧត្តមអគ្គានុរក្ស)

របៀបរៀបចំរូបភាពសញ្ញាសក្តិ : រៀបតាមលំដាប់ពីក្រោមមកលើ

- ទទឹងធ្នូតប្រវែង ០២ ម.ម
- ចន្លោះពីធ្នូតមួយទៅធ្នូតមួយប្រវែង ១.៥ ម.ម
- ពីធ្នូតទី ៣ ទៅធ្នូតទី ៤ ឃ្លាតគ្នាប្រវែង ០៣ ម.ម

**គ- សក្តិថ្នាក់អគ្គានុរក្សពន្ធនាគារ មាន ២ ប្រភេទ**

*១. សក្តិស្មាប្រភេទ ២*

សក្តិស្មាប្រភេទ២ ប្រើប្រាស់បំពេញការងារប្រចាំថ្ងៃ ហើយពាក់នៅលើឯកសណ្ឋានលេខ៤ និងលេខ៥។ សក្តិស្មាប្រភេទនេះធ្វើអំពីក្រណាត់កាំម្វីពណ៌ខៀវចាស់ មានរាងចតុកោណព្នាយជ្រុងខាងចុងមានរូបកូនសោរពីរ(ចុងសោរឡើងលើ)ខ្វែងគ្នាទ្រជើងពានតម្កល់វដ្តធម្មនុញ្ញក្នុងម្កុដរាជ ពណ៌ប្រាក់ មានឡេវរូបព្រះសង្ការពណ៌ប្រាក់ និងមានក្បាច់ផ្កាភ្ញីវល្លិពណ៌ប្រាក់ កាត់ទទឹងផ្នែកខាងដើមផ្ទៃសក្តិ ហើយធ្នូតពណ៌មាសសក្តិកាត់ទទឹងផ្ទៃសក្តិជាសញ្ញាសម្គាល់សក្តិថ្នាក់អគ្គានុរក្ស។ ដោយឡែក សក្តិអគ្គានុរក្សថ្នាក់លេខ ៤ មានធ្នូតពណ៌ប្រាក់។

អំពីទំហំខ្នាត : (ដូចសក្តិថ្នាក់វរអគ្គានុរក្ស)

របៀបរៀបចំរូបភាពសក្តិ :

- អគ្គានុរក្សថ្នាក់លេខ១ មានធ្នូតពណ៌មាស ៣
- អគ្គានុរក្សថ្នាក់លេខ២ មានធ្នូតពណ៌មាស ២

- អគ្គានុរក្សថ្នាក់លេខ៣ មានធ្នូតពណ៌មាស ១
- អគ្គានុរក្សថ្នាក់លេខ៤ មានធ្នូតពណ៌ប្រាក់ ១ ហើយនៅចំកណ្តាលបណ្តោយធ្នូតសក្តិមានគំនូស ពណ៌លឿងមួយ ទំហំទទឹងប្រវែង ៣០ម.ម ។

*៣. សក្តិប្រភេទ៣ "សក្តិទ្រូង"*

សក្តិប្រភេទ៣នេះ សម្រាប់ពាក់នៅលើទ្រូងនៃឯកសណ្ឋានលេខ៦ "ឯកសណ្ឋានប្រតិបត្តិការ"។ សក្តិប្រភេទនេះ មានរាងបួនជ្រុងស្មើ ធ្វើអំពីក្រណាត់កាំម្ទីពណ៌ខៀវចាស់ ហើយមានធ្នូតកាត់ទទឹងជាសញ្ញាសម្គាល់សក្តិ និងមានកូនសោរពីរ (ក្បាលសោរឡើងលើ) ខ្វែងគ្នាទ្រជើងពានតម្កល់ដ្ឋេធម្មនុញ្ញក្នុងម្កុដរាជ និងមានក្បាច់ផ្កាភ្ញីវល្លិពណ៌ប្រាក់(ប៉ាក់ដោយខ្សែសយ)។

អំពីទំហំខ្នាត : (ដូចសក្តិថ្នាក់វរអគ្គានុរក្ស)

**គ. សក្តិថ្នាក់អនុរក្សពន្ធនាគារ មាន ២ ប្រភេទ**

*១. សក្តិស្មាប្រភេទ ២*

សក្តិស្មាប្រភេទ២ ព្រះរាជពិធីបុណ្យជាតិ ពិធីផ្លូវការនានា ពិធីទទួលភ្ញៀវជាតិ អន្តរជាតិ ពិធីមិទ្ទីញ សិក្ខាសាលា សន្និបាតនានា និងបំពេញការងារប្រចាំថ្ងៃ ហើយពាក់នៅលើឯកសណ្ឋានលេខ ៤ និងលេខ៥។ សក្តិស្មាប្រភេទនេះធ្វើអំពីក្រណាត់កាំម្ទីពណ៌ខៀវចាស់ មានរាងចតុកោណព្នាយជ្រុងខាងចុងមានកូនសោរពីរ(ចុងសោរឡើងលើ)ខ្វែងគ្នាទ្រជើងពានតម្កល់រដ្ឋធម្មនុញ្ញក្នុងម្កុដរាជពណ៌ប្រាក់មានឡេវរូបព្រះសង្ហារពណ៌ប្រាក់ មានធ្នូតកាច់ជាសញ្ញាសម្គាល់សក្តិ និងមានក្បាច់ផ្កាភ្ញីវល្លិពណ៌ប្រាក់។

អំពីទំហំខ្នាត : (ដូចសក្តិថ្នាក់អគ្គានុរក្សពន្ធនាគារ)

របៀបរៀបចំរូបភាពសក្តិ :

- អនុរក្សថ្នាក់លេខ១ មានធ្នូតកាច់ ៣ ពណ៌លឿង
- អនុរក្សថ្នាក់លេខ២ មានធ្នូតកាច់ ២ ពណ៌លឿង
- អនុរក្សថ្នាក់លេខ៣ មានធ្នូតកាច់ ១ ណ៌លឿង

*២. សក្តិប្រភេទ៣ "សក្តិទ្រូង"*

សម្រាប់ពាក់នៅលើទ្រូងនៃឯកសណ្ឋានលេខ៦ "ឯកសណ្ឋានប្រតិបត្តិការ"។ សក្តិនេះមានរាងបួនជ្រុងស្មើ ធ្វើអំពីក្រណាត់កាំម្ទីពណ៌ខៀវចាស់មានកូនសោរពីរ (ចុងសោរឡើងលើ) ខ្វែងគ្នាទ្រជើងពានតម្កល់រដ្ឋធម្មនុញ្ញក្នុងម្កុដរាជប៉ាក់ពណ៌ប្រាក់ ហើយមានធ្នូតកាច់ជាសញ្ញាសម្គាល់សក្តិនិងមានក្បាច់ផ្កាភ្ញីវល្លិពណ៌ប្រាក់កាត់ទទឹងផ្ទៃសក្តិខាងដើម។

អំពីទំហំខ្នាត : (ដូចសក្តិថ្នាក់អគ្គានុរក្ស)

**ប្រការ៤.-**

មន្ត្រីពន្ធនាគារត្រូវបានទទួលរបបផ្គត់ផ្គង់នូវ ឯកសណ្ឋាន ស្លាកសញ្ញា សញ្ញាសក្តិ និងសម្ភារប្រើប្រាស់ផ្សេងៗ ដូចខាងក្រោម :

**ក. ឯកសណ្ឋាន និងស្លាកសញ្ញាសម្គាល់**

១- ឯកសណ្ឋានធំលេខ ១ "ការ៉ីពណ៌ស" ចំនួន ០១ កំប្លេរ សម្រាប់រយៈពេល ០៥ឆ្នាំ

២- ឯកសណ្ឋានធំលេខ ២ "ការ៉ីពណ៌ខ្លាញ់ក្តាមចាស់ " ចំនួន០១ កំប្លេរ សម្រាប់រយៈពេល ០៥ឆ្នាំ

៣- ឯកសណ្ឋានលេខ ៣ "សាហារីយែន" ចំនួន ០១ កំប្លេរ សម្រាប់រយៈពេល ០១ឆ្នាំ

៤-ឯកសណ្ឋានការងារលេខ ៤ និងលេខ៥ មួយមុខ ចំនួន ០១ កំប្លេរ សម្រាប់រយៈពេល ០១ឆ្នាំ

៥- ឯកសណ្ឋានលេខ ៦ "ប្រតិបត្តិការ" ចំនួន ០២ កំប្លេ សម្រាប់រយៈពេល ០១ឆ្នាំ(សម្រាប់មន្ត្រីផ្នែកសន្តិសុខ អន្តរាគមន៍)
៦- អាវយឺតដៃខ្លី កឌុប ពណ៌ប្រផេះ ចំនួន ០២ សម្រាប់រយៈពេល ០១ឆ្នាំ
៧- ស្លាកសញ្ញាសម្គាល់ប្រភេទ ១ ចំនួន ០១ សម្រាប់រយៈពេល ០៤ឆ្នាំ
៨- ស្លាកសញ្ញាសម្គាល់ប្រភេទ ៤ ចំនួន ០១គូ សម្រាប់រយៈពេល ០៣ឆ្នាំ
៩- ស្លាកសញ្ញាសម្គាល់ប្រភេទ ៥ ចំនួន ០១ សម្រាប់រយៈពេល ០២ឆ្នាំ
១០- សញ្ញាសម្គាល់អតីតភាពការងារ ចំនួន ០១ សម្រាប់រយៈពេល ០២ឆ្នាំ។

ខ. សញ្ញាសក្តិ

១- សក្តិស្មាប្រភេទ ១ ចំនួន ០១គូ សម្រាប់រយៈពេល ០៤ ឆ្នាំ(ថ្នាក់វរអគ្គានុរក្សឡើង)
២- សក្តិស្មាប្រភេទ ២ ចំនួន ០១គូ សម្រាប់រយៈពេល ០១ ឆ្នាំ
៣- សក្តិទ្រូង ប្រភេទ ៣ ចំនួន ០១ សម្រាប់រយៈពេល ០១ ឆ្នាំ។

គ. សម្ភារះផ្សេងៗ

១- មួកកាស្កេត ឬមួកសំបុកប្រភេទ ១(ពណ៌ស) ចំនួន ០១ សម្រាប់រយៈពេល ០៥ ឆ្នាំ
២- មួកកាស្កេតប្រភេទ២ ឬមួកសំបុកប្រភេទ២ ឬមួកហ្សកកី ចំនួន ០១ សម្រាប់រយៈពេល ០១ ឆ្នាំ
៣- មួកដែក(ស្មាច់)ពណ៌បៃតងចាស់"សម្រាប់មន្ត្រីប្រតិបត្តិការ" ចំនួន ០១ សម្រាប់រយៈពេល ០២ ឆ្នាំ
៤- ស្បែកជើងកខ្លី ចងខ្សែ (សម្រាប់បុរស) និងស្រោមជើង ចំនួន ០២គូ សម្រាប់រយៈពេល ០១ ឆ្នាំ
៥- ស្បែកជើងកវែង ខ្សែរូត(សម្រាប់មន្ត្រីប្រតិបត្តិការ)និងស្រោមជើង ចំនួន ០១គូ សម្រាប់រយៈពេល ០១ ឆ្នាំ
៦- ស្បែកជើងអេស្កាប៉ាំង (សម្រាប់នារី)និងស្រោមជើងវែង ចំនួន ០២គូ សម្រាប់រយៈពេល ០១ ឆ្នាំ
៧- ខ្សែក្រវ៉ាត់តូចនិងក្បាល ចំនួន ០១ សម្រាប់រយៈពេល ០១ ឆ្នាំ
៨- ខ្សែក្រវ៉ាត់ធំ "សាំងទៀរ៉ុង" ពាក់ជាមួយឯកសណ្ឋានប្រតិបត្តិការ មួយមុខ ចំនួន ០១ សម្រាប់រយៈពេល ០១ ឆ្នាំ
៩- ក្រវ៉ាត់ក និងឃ្នាប មួយមុខ ចំនួន ០១ សម្រាប់រយៈពេល ០២ ឆ្នាំ
១០- អាវសឺមីកឌុប ពណ៌ស ចំនួន ០១ សម្រាប់រយៈពេល ០២ ឆ្នាំ
១១- អាវសឺមីកឌុប ពណ៌ផ្ទៃមេឃ ចំនួន ០១ សម្រាប់រយៈពេល ០២ ឆ្នាំ
១២- ខ្សែឥស្សរិយយស ចំនួន ០១ សម្រាប់រយៈពេល ០៥ ឆ្នាំ
១៣- ខ្សែកញ្ចែ និងកញ្ចែ ចំនួន ០១ សម្រាប់រយៈពេល ០១ ឆ្នាំ សម្រាប់មន្ត្រីសន្តិសុខ អន្តរាគមន៍
១៤- កន្សែងពោះគោធំ ចំនួន ០២ សម្រាប់រយៈពេល ០១ ឆ្នាំ
១៥- សារុងពុម្ព(សម្រាប់នារី) ចំនួន ០២ សម្រាប់រយៈពេល ០១ ឆ្នាំ
១៦- មុង (0.80ម x 1.80ម) សម្រាប់មន្ត្រីនៅមណ្ឌលអប់រំកែប្រែ ពន្ធនាគាររាជធានី ខេត្ត ចំនួន ០១ សម្រាប់រយៈពេល ០១ ឆ្នាំ
១៧- ភួយអំបោះ(0.96ម x 1.85ម) សម្រាប់មន្ត្រីនៅមណ្ឌលអប់រំកែប្រែ ពន្ធនាគាររាជធានីខេត្តចំនួន ០១ សម្រាប់រយៈពេល ០១ ឆ្នាំ
១៨- កន្ទេល(0.95ម x 1.84ម) ចំនួន ០១ សម្រាប់រយៈពេល ០១ ឆ្នាំ

១៩- អគ្រឹងនិងខ្សែ(1.40ម x 2.39ម) សម្រាប់មន្ត្រីនៅមណ្ឌលអប់រំកែប្រែ ពន្ធនាគាររាជធានី ខេត្ត និងមន្ត្រីប្រតិបត្តិការ(នៅថ្នាក់កណ្ដាល) ចំនួន ០១ សម្រាប់រយៈពេល ០១ ឆ្នាំ

២០- អាវភ្លៀងប៉ុងសូ(1.40ម x 2.00ម) ចំនួន ០១ សម្រាប់រយៈពេល ០១ ឆ្នាំ

២១- ពិល ចំនួន ២០% នៃមន្ត្រីពន្ធនាគារនៅមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត សម្រាប់រយៈពេល ០១ ឆ្នាំ

២២- តង់ក្រណាត់កៅស៊ូធំសម្រាប់បោះជំរំ(4ម x 6ម) ចំនួន ១០% នៃមន្ត្រីពន្ធនាគារនៅមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត សម្រាប់រយៈពេល ០១ ឆ្នាំ។

២៣- ដំបងឆក់ ចំនួន ១០% នៃមន្ត្រីពន្ធនាគារនៅមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត សម្រាប់រយៈពេល ០១ ឆ្នាំ។

២៤- ខ្នោះដៃ ចំនួន ២០%នៃមន្ត្រីពន្ធនាគារនៅមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត

២៥- វិទ្យុទាក់ទង ចំនួន ១០% នៃមន្ត្រីពន្ធនាគារនៅមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត។

ក្រៅពីសម្ភារៈប្រើប្រាស់ដូចខាងលើ មន្ត្រីពន្ធនាគារត្រូវបានបំពាក់បន្ថែមនូវសម្ភារៈបច្ចេកទេស និងឧបករណ៍ពារាំងសមស្របផ្សេងៗទៀតទៅតាមតម្រូវការចាំបាច់ជាក់ស្ដែង។

**ប្រការ៥.—**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦.—**

រាល់ការផលិតឯកសណ្ឋាន ស្លាកសញ្ញា និងសញ្ញាសក្តិរបស់មន្ត្រីពន្ធនាគារខុសពីរូបភាព ទំហំខ្នាត ដែលកំណត់ក្នុងប្រការ១ ប្រការ២ និងប្រការ៣ នៃប្រកាសនេះត្រូវហាមឃាត់។

ជនណាផលិត ឬប្រើប្រាស់ឯកសណ្ឋាន ស្លាកសញ្ញា និងសញ្ញាសក្តិរបស់មន្ត្រីពន្ធនាគារដូចកំណត់ខាងលើ ដោយគ្មានការអនុញ្ញាតត្រូវទទួលទោសចំពោះមុខច្បាប់ជាធរមាន។

**ប្រការ៧.—**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានកស្ដុការ និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត គ្រប់អង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែ សីហា ឆ្នាំ ២០១៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

<u>**កន្លែងទទួល**</u> :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ